ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ [illegible]

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៨.៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ១.០១០.១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋាន

**ស ម្រេ ច**

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះ ហៅថា **"គណៈកម្មាធិការ"** ។

**ប្រការ ២.-**

គណៈកម្មាធិការនេះ រួមមានសមាសភាពចំនួន ៩រូប ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ | ទេសាភិបាលរង | អនុប្រធាន |
| ៣. លោក អ៊ូ ចាន់តារា | អគ្គលេខាធិការ | សមាជិក |
| ៤. លោកជំទាវ ជា សិរី | អគ្គនាយកបច្ចេកទេស | សមាជិក |



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

| | | |
|---|---|---|
| ៥. លោក រ័ត្ន សុវណ្ណនរៈ | អគ្គនាយកត្រួតពិនិត្យ | សមាជិក |
| ៦. លោក គីមទី កោមលី | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៧. លោក យូ វុណ្ណី | អគ្គនាយករងបច្ចេកទេស និងជាប្រធាននាយកដ្ឋានស.ស.អ | សមាជិកអចិន្ត្រៃយ៍ |
| ៨. លោក ម៉ក់ វត្ថា | ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក និង |
| ៩. លោក លី ស៊ីដេត | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | សមាជិក ។ |

**ប្រការ ៣.~**

គណៈកម្មាធិការនេះ អាចដំណើរការកិច្ចប្រជុំបានលុះត្រាតែមាន ទេសាភិបាល ជាប្រធាន និងមានសមាជិកយ៉ាងតិចចំនួន ៦រូប ។ សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។ ប្រធានគណៈកម្មាធិការអាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញផ្សេងទៀត ចូលរួមក្នុងការប្រជុំតាមការចាំបាច់ ។

**ប្រការ ៤.~**

ការប្រជុំរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងយ៉ាងហោចណាស់បីខែម្តង ដើម្បីរាយការណ៍ពី ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុ ។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មាធិការអាចកោះប្រជុំគណៈកម្មាធិការនៅពេលណាក៏បាន ។

**ប្រការ ៥.~**

គណៈកម្មាធិការមានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- កំណត់និងដឹកនាំការអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ក្នុងក្របខ័ណ្ឌនៃគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល សំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច
- ដាក់ចេញនូវវិធានការចាំបាច់ សំដៅធ្វើឱ្យស្ថានភាពសន្ទនីយភាពក្នុងទីផ្សាររូបិយវត្ថុ ស្របតាមគោលដៅនៃការរក្សាស្ថិរភាពថ្លៃ
- សម្របសម្រួលទៅតាមលទ្ធភាពជាមួយសមាសធាតុផ្សេងៗនៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ពិសេសគោលនយោបាយសារពើពន្ធ សំដៅទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
- សម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននៃការត្រួតពិនិត្យធនាគារ និង
- ផ្សព្វផ្សាយគោលនយោបាយរូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

**ប្រការ ៦.~**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការមានក្រុមការងារជំនួយការមកពីនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំងដោយសេចក្តីបង្គាប់ការ និងមានមុខងារ-ភារកិច្ចដូចខាងក្រោម ៖

- តាមដាន ប្រមូល និងចងក្រងព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា និន្នាការសេដ្ឋកិច្ច ស្ថិតិរូបិយវត្ថុ ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មាធិការក្នុងការកំណត់ គោលដៅ យុទ្ធសាស្ត្រ វិធានការ ឬឧបករណ៍គោលនយោបាយរូបិយវត្ថុ

- វិភាគនិងវាយតម្លៃពីបញ្ហាប្រឈម និងផលប៉ះពាល់ដែលនាំឱ្យមានសម្ពាធអតិផរណា ព្រមទាំង លើកឡើងពីជម្រើសនៃការដោះស្រាយជាគោលនយោបាយ ដើម្បីគណៈកម្មាធិការពិនិត្យនិងសម្រេចចេញជា វិធានការអនុវត្ត និង

- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មាធិការ ផ្ញើជូនទៅថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីជ្រាបជាព័ត៌មាននិងសហការអនុវត្ត ។

**ប្រការ ៧.~**

កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការ ត្រូវរៀបចំឱ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៨.~**

ប្រកាសស្តីពីការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ លេខ ធ១៣-០១៤-០៦៩ ប្រ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុង ប្រការ២ ត្រូវអនុវត្តនូវ ខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.~**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០១៧

ទេសាភិបាល

ជា.ចាន់តូ

<u>កន្លែងទទួល</u> :
- ដូចប្រការ ២ និងប្រការ ៩
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

<u>ចម្លងជូន</u> :
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"